UN-ACT
United Nations Action for Cooperation against Trafficking in Persons

# កិច្ចប្រជុំក្រុមអ្នកធ្វើការទារពាក់ព័ន្ធនឹងការប្រឆាំងអំពើជួញដូរមនុស្ស
# លើកទី១ ឆ្នាំ២០១៧

~~សណ្ឋាគារកាំបូឌីយ៉ាណា~~ *No. 313, Preah Sisowath Quay, 12207 Phnom Penh*
ឡេក្លាកាន់

ព្រហស្បត៍ទី០២ ខែមីនា ឆ្នាំ២០១៧

**របៀបវារៈ**

| | |
|---|---|
| 14:00-14:15 | ចុះឈ្មោះអ្នកចូលរួមក្នុងអង្គប្រជុំ |
| 14:15-14:25 | កិច្ចស្វាគមន៍ និងការណែនាំខ្លួន ដោយប្រធានអង្គប្រជុំ |
| 14:25-14:30 | ពិនិត្យ និងអនុម័តលើកំណត់ហេតុកិច្ចប្រជុំលើកមុន |
| 14:30-14:50 | ករណីជួញដូរទៅប្រទេសជប៉ុន- IOM |
| 14:50-15:40 | ទិដ្ឋភាពទូទៅនៃការពរពោះជំនួស-UN-ACT |
| 15:40-16:00 | សម្រាកពិសារអាហារសម្រន់ |
| 16:00-16:30 | ការឆ្លើយតបរបស់រដ្ឋាភិបាលលើបញ្ហាជួលឱ្យពរពោះជំនួស-ដោយ គ.ជ.ប.ជ. |
| 16:30-16:40 | គម្រោងថ្នាក់តំបន់- Winrock |
| 16:40-17:00 | ផ្សេងៗ |
| 17:00 | បិទកិច្ចប្រជុំ |

---

សម្គាល់៖របៀបវារៈ អាចមានការកែប្រែ ក្នុងករណីចាំបាច់

UN-ACT
United Nations Action for Cooperation against Trafficking in Persons

កាលបរិច្ឆេទ៖ ៧ ធ្នូ ២០១៦

ភាសាខ្មែរ

# កំណត់ហេតុ
# កិច្ចប្រជុំអ្នកធ្វើការងារពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

***ថ្ងៃទី ៧ ខែធ្នូ ឆ្នាំ២០១៦***

***សណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ***

សកម្មភាពអង្គការសហប្រជាជាតិដើម្បីសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា (UN-ACT) តែងតែរៀបចំកិច្ចប្រជុំជាមួយក្រុមអ្នកធ្វើការងារពាក់ព័ន្ធនឹងការប្រឆាំងអំពើជួញដូរមនុស្សជាប្រចាំ។ កិច្ចប្រជុំក្រុមអ្នកធ្វើការងារពាក់ព័ន្ធនឹងការប្រឆាំងអំពើជួញដូរមនុស្ស ជាលើកទី៣ ក្នុងឆ្នាំ ២០១៦ ត្រូវបានធ្វើឡើងនៅថ្ងៃទី ៧ ខែធ្នូ ឆ្នាំ ២០១៦ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។ តំណាងដៃគូពាក់ព័ន្ធដែលចូលរួមក្នុងកិច្ចប្រជុំ មានចំនួន ៧០នាក់ មកពីក្រសួង និងស្ថាប័នរដ្ឋ ដោយរួមបញ្ចូលទាំង ក្រុមការងារខមមីតកម្ពុជា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ព្រឹទ្ធសភា អាជ្ញាធរមានសមត្ថកិច្ច ភ្នាក់ងារឯកជន ស្ថាប័នសិក្សាស្រាវជ្រាវ ស្ថាប័នឧត្តមសិក្សា អង្គការជាតិ និងអន្តរជាតិនានា ដែលធ្វើការផ្តោតលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ គោលបំណងសំខាន់នៃកិច្ចប្រជុំនេះ គឺដើម្បីសម្របសម្រួល ចែករំលែកព័ត៌មាន ផ្លាស់ប្តូរយោបល់ និងផ្តល់ជាអនុសាសន៍សម្រាប់ការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជា។

## សេចក្តីផ្តើម

កញ្ញា Joyce Ting នាយិកាផ្នែកការសង្គ្រោះជនរងគ្រោះពីអំពើជួញដូរមនុស្សឆ្លងដែន នៃអង្គការ Agape International Mission (AIM) និងជាអ្នកសម្របសម្រួលកិច្ចប្រជុំ បានមានមតិស្វាគមន៍ និងសំណូមពរឲ្យអ្នកទើបតែចូលរួមប្រជុំលើកដំបូងទាំងអស់ធ្វើការណែនាំខ្លួន បន្ទាប់មកទើបឈានចូលដល់ការពិនិត្យលើរបៀបវារៈនៃកិច្ចប្រជុំ។ កិច្ចប្រជុំចាប់ផ្តើមឡើងដោយការពិនិត្យរបៀបវារៈ និងពិនិត្យឯកភាពលើកំណត់ហេតុនៃកិច្ចប្រជុំពីលើកមុន ព្រមទាំងមានបទការធ្វើបច្ចុប្បន្នភាពអំពី **“កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីតលើកទី១១ នៅប្រទេសឡាវ”** ដោយលោកជំទាវ សាន្ត អរុណ រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារខមមីតកម្ពុជា, បច្ចុប្បន្នភាពអំពី **“កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស”** ដោយលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ), និងកិច្ចពិភាក្សាជាក្រុមរួមទាំងបទបង្ហាញស្តីពី **“បញ្ហាប្រឈម ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរ**

មនុស្ស និងអនុសាសន៍ក្នុងការរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៧” ដែលធ្វើឡើងដោយអ្នកចូលរួមក្នុងអង្គប្រជុំទាំងអស់គ្នា ។

## បទបង្ហាញ និង កិច្ចពិភាក្សា

*១. បច្ចុប្បន្នភាពស្តីពីកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីតលើកទី១១ នៅប្រទេសឡាវ*

លោកជំទាវ សាន្ត អរុណ រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារខមមីតកម្ពុជា បានចាប់ផ្តើមបទបង្ហាញដោយជម្រាបប្រាប់ដល់អង្គប្រជុំដោយសង្ខេបស្តីពីសារតារខ្លះៗនៃកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីតដោយកិច្ចប្រជុំលើកចុងក្រោយបំផុតត្រូវបានធ្វើឡើងកាលពីថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៦ ក្នុងក្រុងវៀងចាន់ប្រទេសឡាវ។ កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីតនិមួយៗមានប្រធានបទផ្សេងៗគ្នា។ ប្រធានបទសម្រាប់កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីតលើកទី១១គឺ “ពង្រឹងយុទ្ធសាស្ត្រផ្តោតលើជនរងគ្រោះ ៖ រៀនសូត្រពីបទពិសោធន៍របស់ដំណើរការខមមីត”។ កិច្ចប្រជុំនេះមានអ្នកចូលរួមប្រមាណ២០០នាក់ដោយរួមបញ្ចូលទាំងគណៈប្រតិភូពីប្រទេសទាំង៦ដែលជាសមាជិកដំណើរការខមមីត (កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម) អង្គការ សមាគមកម្រិតតំបន់ដូចជាអាស៊ាន ដៃគូអភិវឌ្ឍន៍ តំណាងយុវជនទាំង៦ប្រទេស និងតំណាងអង្គការសង្គមស៊ីវិលនានា។ គណៈប្រតិភូកម្ពុជាដឹកនាំដោយលោកជំទាវ សាន្ត អរុណ ដោយផ្ទាល់។ កិច្ចប្រជុំសម្រេចបានលទ្ធផលមួយចំនួនដូចជា៖

- គណៈប្រតិភូទាំង៦ប្រទេសបានឯកភាពលើគោលការណែនាំថ្នាក់តំបន់ស្តីពី កំណត់អត្តសញ្ញាណជនរងគ្រោះនិងយន្តការនិងបញ្ជូនសម្រាប់មហាអនុតំបន់មេគង្គដែលនឹងត្រូវអនុវត្តនៅឆ្នាំ២០១៧ និងក្នុងពេលអនាគត។
- គណៈប្រតិភូទាំងអស់បានឯកភាពគ្នាថាត្រូវអនុវត្តបន្តនូវសំណូមពររបស់តំណាងយុវជនដែលបានបង្ហាញជូននៅក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីតលើកទី១០ ក្នុងឆ្នាំ២០១៥។ ក្នុងនោះរួមមាន ការអញ្ជើញតំណាងយុវជនឱ្យចូលរួមជាសមាជិកក្រុមការងារខមមីត ផ្តល់មូលនិធិដល់យុវជនដើម្បីអនុវត្តសកម្មភាពបង្ការទប់ស្កាត់អំពើជួញដូរមនុស្សក្នុងសហគមន៍របស់ខ្លួនព្រមទាំងឯកភាពបង្កើតយន្តការសមស្របដើម្បីអាចឱ្យរដ្ឋាភិបាលផ្តល់យោបល់និងដំបូន្មាន និងជួយឱ្យយុវជនទទួលបាននូវចំណេះដឹងនិងជំនាញលើកកម្ពស់ការយល់ដឹងស្តីពីការធ្វើទេសន្តប្រវេសន៍ដោយសុវត្ថិភាព ដោយបញ្ចូលប្រធានបទស្តីពីអំពើជួញដូរមនុស្សនិងទេសន្តប្រវេសន៍ទៅក្នុងកម្មវិធីសិក្សា។
- ប្រទេសសមាជិកខមមីត នឹងត្រូវពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល និងត្រូវជានាឱ្យមានការចូលរួមរបស់ពួកគេនៅក្នុងឆ្នាំ២០១៧។
- ប្រទេសសមាជិកខមមីតទាំងអស់ឯកភាពព្រមព្រៀងថាកិច្ចសហការជាមួយវិស័យឯកជនពិតជាមានសារៈសំខាន់ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងត្រូវពង្រឹងបន្ថែមទៀតក្នុងឆ្នាំ២០១៧។
- ប្រទេសសមាជិកខមមីតឯកភាពជាគោលការណ៍ថាដំណើរការខមមីតនឹងត្រូវបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយអាស៊ានតាមដែលអាចធ្វើទៅបាន ហើយក៏បានស្នើដល់អាស៊ានឱ្យធ្វើការងារយ៉ាងជិតស្និទ្ធជាមួយដំណើរការខមមីតផងដែរ។ ប្រទេសជាសមាជិកខមមីតទាំងអស់បានឯកភាពលើសំណើជម្រុញកិច្ចសហប្រតិបត្តិការជាមួយអាស៊ាន។

- ពាក់ព័ន្ធនឹងនិរន្តរភាព និងការលើកម្ពស់សមត្ថភាព ប្រទេសទាំងអស់បានឯកភាពអនុវត្តតាមផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៧ ដោយផ្អែកលើអទិភាពនៃអនុសាសន៍ទាំងឡាយដែលបានលើកឡើងនៅក្នុងរបាយការណ៍ស្តីពីការអភិវឌ្ឍន៍សមត្ថភាពរបស់ UN-ACT ដែលបានធ្វើការសិក្សាស្រាវជ្រាវស្តីពីតម្រូវការក្នុងការអភិវឌ្ឍន៍សមត្ថភាពបន្ថែមនៅក្នុងប្រទេសទាំងអស់ដែលជាសមាជិកដំណើរការខមមីត។

## *២. កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស*

លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានធ្វើបច្ចុប្បន្នភាពជូនដល់អង្គប្រជុំទាំងមូលអំពីកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដោយរួមបញ្ចូលទាំងការប្រើយុទ្ធសាស្ត្រដែលផ្តោតដល់ការជួយដល់ជនរងគ្រោះជាចម្បង (victim-centered approach) របស់ គ.ជ.ប.ជ។ រាជរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងខិតខំប្រឹងប្រែងយ៉ាងអស់ពីកំលាំងកាយចិត្តដើម្បីការពារ និងលើកស្ទួយការគោរពសិទ្ធិជនរងគ្រោះក៏ដូចជាខិតខំស្វែងរកសេវាសមស្របនិងចាំបាច់ដល់ជនរងគ្រោះ ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការដៃគូនានា។ គ.ជ.ប.ជ គ្រោងនឹងរៀបចំសិក្ខាសាលាមួយនៅថ្ងៃទី២១ ខែធ្នូ ដោយផ្តោតលើការពង្រឹងការអនុវត្តន៍ច្បាប់ដើម្បីស្វែងរកយុត្តិធម៌ និងសំណងដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ សិក្ខាសាលានោះក៏នឹងមានការពិភាក្សាផងដែរស្តីពីបញ្ហាប្រឈមទាំងឡាយដែលជាឧបសគ្គរាំងស្ទះដល់ការផ្តល់សំណងដល់ជនរងគ្រោះ។

លោកជំទាវ ក៏បានបន្តជម្រាបដល់អង្គប្រជុំទាំងមូលអំពីការងារនានាដែល គ.ជ.ប.ជ បាននិងកំពុងបន្តធ្វើដោយមានរចនាសម្ព័ន្ធទូលំទូលាយតាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិ។ ចាប់តាំងពី គ.ជ.ប.ជ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៤ គណៈកម្មាធិការនេះមានក្រុមការងារជំនាញអន្តរក្រសួងស្ថាប័នចំនួន៦។ ក្រុមការងារបង្ការទប់ស្កាត់ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ក្រុមការងារការពារជនរងគ្រោះដឹកនាំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុមការងារអនុវត្តច្បាប់ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រុមការងារកិច្ចការយុត្តិធម៌ដឹកនាំដោយក្រសួងយុត្តិធម៌ ក្រុមការងារកិច្ចសហការអន្តរជាតិដឹកនាំដោយក្រសួងកិច្ចការនារី និងក្រុមការងារទេសន្តរប្រវេសន៍ដឹកនាំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ កម្ពុជាបានប្រកាសដាក់ឱ្យអនុវត្ត "គោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប" ហើយកន្លងមក គ.ជ.ប.ជ បានរៀបចំវគ្គបណ្តុះបណ្តាលក្នុងខេត្តចំនួនបីដល់មន្ត្រីជួរមុខ និងវគ្គបណ្តុះបណ្តាលមួយសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ដែលជាអ្នកផ្តល់សេវាដល់ជនរងគ្រោះ។

ពាក់ព័ន្ធនឹងកិច្ចបង្ការទប់ស្កាត់ គ.ជ.ប.ជ កំពុងធ្វើការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលស្តីពីអំពើជួញដូរមនុស្សដល់គរុនិស្សិតនៅតាមមណ្ឌលគរុកោសល្យ។ គ.ជ.ប.ជ មានគម្រោងរៀបចំប្រារព្ធទិវាជាតិប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ នៅកោះពេជ្រដោយមានអ្នកចូលរួមប្រមាណជា៣០០០នាក់។ ទិវានោះនឹងមានការអញ្ជើញជាគណៈអធិបតីពីសំណាក់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ។

ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ កម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគី ជាមួយប្រទេសមួយចំនួនដើម្បីពង្រឹងកិច្ចសហការប្រឆាំងអំពើជួញដូរមនុស្ស។ ជាឧទាហរណ៍ជាក់ស្តែង កម្ពុជាបានចុះហត្ថលេខា

លើកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសចិន និងវៀតណាម។ កម្ពុជាក៏កំពុងធ្វើការងារលើកិច្ចព្រមព្រៀងទ្វេភាគីមួយទៀតជាមួយប្រទេសឥណ្ឌា ដើម្បីឆ្លើយតបទៅនឹងករណីជួញដូរសេវាកម្មមនុស្ស។

ស្របពេលជាមួយគ្នានេះ គ.ជ.ប.ជ ក៏កំពុងធ្វើការវាយតម្លៃពាក់កណ្តាលអណត្តិទៅលើការអនុវត្តន៍ផែនការសកម្មភាពជាតិផងដែរ។ នៅចុងបញ្ចប់ លោកជំទាវ ជូ ប៊ុនអេង បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់សម្រាប់ការគាំទ្រ និងការប្តេជ្ញាតាំងចិត្តខ្ពស់ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។

### *៣. កិច្ចពិភាក្សាជាក្រុមស្តីពី បញ្ហាប្រឈមក្នុងឆ្នាំ២០១៦ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអនុសាសន៍ក្នុងការរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៧*

សមាជិកអង្គប្រជុំទាំងអស់ត្រូវបានបែងចែកជាក្រុមតូចៗដើម្បីពិភាក្សាពីបញ្ហាប្រឈមដែលពួកគេបានជួបប្រទះក្នុងកិច្ចការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងឆ្នាំ២០១៦ និងលើកជាអនុសាសន៍សម្រាប់សកម្មភាពដែលនឹងត្រូវអនុវត្តក្នុងឆ្នាំ២០១៧ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឱ្យកាន់តែមានប្រសិទ្ធភាព។ សមាជិកអង្គប្រជុំទាំងអស់នៅក្នុងក្រុមនីមួយៗត្រូវបានស្នើឱ្យពិភាក្សាផ្តែកលើបរិបទ៤ផ្នែកផ្សេងគ្នា គឺ៖ ១)ការបង្ការទបស្កាត់ ២)ការការពារ ៣)ការផ្តន្ទាទោស និង៤)គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ។ បន្ទាប់ពីកិច្ចពិភាក្សាត្រូវបានបញ្ចប់ ក្រុមនីមួយៗត្រូវបានស្នើឱ្យធ្វើបទបង្ហាញជូនដល់អង្គប្រជុំទាំងមូលពីលទ្ធផលដែលក្រុមខ្លួនបានពិភាក្សា។ ភាគីពាក់ព័ន្ធនឹងយកលទ្ធផលនៃកិច្ចពិភាក្សានោះទៅបង្កើតកម្មវិធីផ្សេងៗតាមបរិបទរបស់ខ្លួន។ ជាពិសេស លទ្ធផលនៃកិច្ចពិភាក្សានោះនឹងអាចជាប្រយោជន៍សំខាន់ដល់ការធ្វើផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៧ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ខាងក្រោមនេះជាលទ្ធផលសង្ខេបនៃកិច្ចពិភាក្សា៖

*<u>គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ</u>*

- បញ្ហាប្រឈម៖ កង្វះគោលនយោបាយ និងច្បាប់ដើម្បីឆ្លើយតបនឹងបញ្ហាដែលទើបកើតមានឡើង
    - ដំណោះស្រាយ៖ បង្កើត និងពិនិត្យច្បាប់និងគោលនយោបាយពាក់ព័ន្ធ
- បញ្ហាប្រឈម៖ ទិដ្ឋភាពផ្នែកគត្តិយុត្តិ (**Legal framework**) មានភាពខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ
    - ដំណោះស្រាយ៖ ពង្រឹងកិច្ចសហប្រតិបត្តិជាមួយប្រទេសផ្សេងៗដែលពាក់ព័ន្ធ
- បញ្ហាប្រឈម៖ ប្រសិទ្ធភាពនៃការអនុវត្តន៍គោលនយោបាយ និងអនុស្សារណៈនៃការយោគយល់គ្នា នៅមានកម្រិត
    - ដំណោះស្រាយ៖ កៀងគរធនធាន និងចែករំលែកបទពិសោធន៍

*<u>ការបង្ការ ទប់ស្កាត់</u>*

- បញ្ហាប្រឈម៖ ពិបាកក្នុងការពិភាក្សាពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ខណៈដែលជម្រើសដែលមាន សុទ្ធតែមានហានិភ័យ និងពិបាកទទួលយក (ការចំណាយ និងពេលវេលា)

- ដំណោះស្រាយ៖ ប្តូរប្រធានបទទៅជាការធ្វើការងារប្រកបដោយសុវត្ថិភាព ជម្រាបប្រាប់ពីឱកាសការងារដែលមាន ផ្តល់វគ្គបណ្តុះបណ្តាលផ្នែកជំនាញផ្សេងៗ ធ្វើការជាមួយនយោជកដើម្បីពិនិត្យតាមដាន និងការពារការបំពាន

- បញ្ហាប្រឈម៖ ភាពងាយរងគ្រោះមានការផ្លាស់ប្តូរ ដោយផ្អែកស្ថានភាពប្រជាសាស្ត្រផ្សេងៗគ្នា (អាយុ ការអប់រំ ។ល។ ឧទាហរណ៍៖ការជួញដូរសិស្សទៅប្រទេស ជប៉ុន កូរេ....)
  - ដំណោះស្រាយ៖ បង្កើតយុទ្ធនាការផ្តោតលើក្រុមគោលដៅនីមួយៗ ប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទំនាក់ទំនងសង្គម (Social Media) ។ល។
- បញ្ហាប្រឈម៖ កម្រិតប្រសិទ្ធភាពនៃយុទ្ធនាការបង្ការទប់ស្កាត់។ អ្វីជាទំហំនៃបញ្ហា? គ្មានឥទ្ធពលបង្ហាញឱ្យឃើញជាក់លាក់
  - ដំណោះស្រាយ៖ កិច្ចការបង្ការទប់ស្កាត់មានប្រសិទ្ធជាបណាវាអាចប្តូរគំនិតនិងការសម្រេចចិត្តរបស់បុគ្គលម្នាក់ៗ។ ពិបាកវាស់ស្ទង់ឬបង្ហាញឱ្យឃើញជាក់ស្តែង។ ម្ចាស់ជំនួយត្រូវយល់ពីបញ្ហានេះ។ ត្រូវការឱ្យមានសូចនាករ និងដំណើរការប្រមូលទិន្នន័យ ដែលមានការឯកភាពព្រមព្រៀងគ្នា ដើម្បីឱ្យយើងអាចប្រៀបធៀប និងវាស់ស្ទង់ឥទ្ធពលឬផលប៉ះពាល់។
- បញ្ហាប្រឈម៖ វាជាការល្អក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះបន្ថែម ប៉ុន្តែ តើយើងត្រូវបញ្ជូនបន្តទៅណា? កង្វះសេវាប្រកបដោយគុណភាព ខ្វះបុគ្គលិកសង្គម ខ្វះធនធាន។ សំខាន់ត្រូវកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាលបន្ថែម តែជាញឹកញាប់មានការផ្លាស់ប្តូរមន្ត្រីពីម្នាក់ទៅម្នាក់ផ្សេងទៀត។ ខ្វះធនធាននាំឱ្យរាំងស្ទះដល់ការងារ។
  - ដំណោះស្រាយ៖ បង្កើតសេវាតាមសហគមន៍ បង្កើនសមត្ថភាពមន្ត្រីរដ្ឋាភិបាល ត្រូវចាត់ចែងថវិកាបន្ថែម
- បញ្ហាប្រឈម៖ ការចូលរួមរបស់សហគមន៍និងអាជ្ញាធរក្នុងការបង្ការទប់ស្កាត់នៅមានកម្រិត
  - ដំណោះស្រាយ៖បង្កើនការចូលរួមតាមរយៈការអប់រំ និងការស្វែងរកការគាំទ្រមតិ នៅក្នុងសហគមន៍និងអាជ្ញាធរមូលដ្ឋាន
- បញ្ហាប្រឈម៖ ការអប់រំក្នុងចំណោមប្រជាជននៅតាមសហគមន៍មានកម្រិតទាប
  - ដំណោះស្រាយ៖ បង្កើនសកម្មភាពលើកកម្ពស់ការយល់ដឹងនៅតាមកម្រិតសហគមន៍ បញ្ចូលបញ្ហាជួញដូរមនុស្សទៅក្នុងកម្មវិធីសិក្សា ពិនិត្យតាមដានការផ្សព្វផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនជ្រើសរើសពលករ និងផ្សព្វផ្សាយបញ្ជីឈ្មោះក្រុមហ៊ុនដែលមានអជ្ញាប័ណ្ណស្របច្បាប់

កំណត់សម្គាល់បន្ថែម៖

- អំពើជួញដូរផ្លូវភេទមានការផ្លាសប្តូរបច្ចេកទេសនិងទ្រង់ទ្រាយ ហើយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនជួបបញ្ហាលំបាកក្នុងការជួយសង្គ្រោះជនរងគ្រោះ។ អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនប្តូរគោលដៅរបស់ខ្លួនដោយផ្តោតលើការជួញដូរពលកម្ម ហើយធ្វើការច្រើនលើការបង្ការទប់ស្កាត់។ ប៉ុន្តែអង្គការមួយចំនួន ធ្វើការតាមរយៈក្រុមសង្គ្រោះក្នុងតំបន់ដែលមានហានិភ័យខ្ពស់ ដោយមានវត្តមានបុគ្គលិកខ្លួននៅទីនោះហើយជួយសង្គ្រោះជនរងគ្រោះបានយ៉ាងច្រើន។

- ការផ្តល់តែការគាំទ្រផ្នែកជីវភាពមួយមុខមិនគ្រប់គ្រាន់ទេ។ សម្រាប់ជនរងគ្រោះដោយសារការជួញដូរពលកម្ម ពួកគេត្រូវការការសិក្សាវាយតម្លៃលើតម្រូវការ ព្រមទាំងជំនួយផ្នែកសុខភាពពងកាយនិងសុខភាពផ្លូវចិត្ត ពុំនោះទេការជួយផ្នែកជីវភាពនឹងក្លាយជាការខ្ជះខ្ជាយឥតប្រយោជន៍។
- ក្នុងករណីឆ្លងដែន យើងមានការលំបាកក្នុងការកសាងទំនុកចិត្តល្អជាមួយអ្នកដែលកំពុងត្រូវបានគេជួយ ឬកំពុងជាប់ឃុំ (អាស្រ័យដោយបទពិសោធន៍អាក្រក់ និងការធ្លាប់បាត់បង់ទំនុកចិត្ត)

*ការផ្តន្ទាទោស*
- បញ្ហាប្រឈម៖ កង្វះភស្តុតាង និងកង្វះជាតុផ្សំនៃបទល្មើស
- បញ្ហាប្រឈម៖ ពិបាកក្នុងការប្រមូលភស្តុតាង
- បញ្ហាប្រឈម៖ មិនមានការទុកដាក់ករណីឬកត់ត្រាឱ្យបានគ្រប់ជ្រុងជ្រោយ
- ដំណោះស្រាយ៖ ពង្រឹងសមត្ថភាពមន្ត្រីពង្រឹងការអនុវត្តន៍ច្បាប់
- ដំណោះស្រាយ៖ ពង្រឹងកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ
- ដំណោះស្រាយ៖ ផ្តល់សម្ភារៈបន្ថែមដល់មន្ត្រីពង្រឹងការអនុវត្តន៍ច្បាប់
- ដំណោះស្រាយ៖ បង្កើនការចែករំលែកនិងផ្លាស់ប្តូរព័ត៌មាន
- ដំណោះស្រាយ៖ ត្រូវការកិច្ចសហប្រតិបត្តិការឆ្លងដែនដែលមានភាពរហ័ស បង្កើតក្រុមការងារសម្រាប់ករណីឆ្លងដែន ប្រើប្រាស់ភស្តុតាង/សាក្សីតាមប្រព័ន្ធវីដេអូ
- ដំណោះស្រាយ៖ ត្រូវមានវគ្គបណ្តុះបណ្តាលសម្រាប់នគរបាលអន្តោប្រវេសន៍ និងមន្ត្រីប្រចាំការនៅតាមអាកាសយានដ្ឋាន

*ការការពារ*
- បញ្ហាប្រឈម៖ កង្វះមណ្ឌលជម្រករបស់រដ្ឋាភិបាលសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- បញ្ហាប្រឈម៖ សេវាសម្រាប់ជួយដល់ជនរងគ្រោះនៅមានកម្រិត
- បញ្ហាប្រឈម៖ ខ្វះកិច្ចសហការពីជនរងគ្រោះ គ្រួសារ និងអាជ្ញាធរមូលដ្ឋាន
- ដំណោះស្រាយ៖ ស្វែងរកការគាំទ្រមតិដើម្បីបង្កើតមណ្ឌលជ្រ
- ដំណោះស្រាយ៖ បង្កើនសេវាបន្ថែមដល់ជនរងគ្រោះ
- ដំណោះស្រាយ៖ បង្កើតគោលនយោបាយ និងច្បាប់សម្រាប់ការពារសាក្សី និងជនរងគ្រោះ

## សន្និដ្ឋានបញ្ចប់

អ្នកសម្របសម្រួលកិច្ចប្រជុំ កញ្ញា Joyce Ting បានថ្លែងអំណរគុណដល់អ្នកធ្វើបទបង្ហាញ និង អ្នកចូលរួមក្នុងអង្គប្រជុំទាំងអស់គ្នា សម្រាប់ការចូលរួម ការផ្តល់មតិយោបល់ និងចំណាប់អារម្មណ៍ផ្សេងៗនៅក្នុងកិច្ចប្រជុំនេះ។ កិច្ចប្រជុំបានបញ្ចប់ជាស្ថាពរនៅវេលាម៉ោង ៥ល្ងាច នាថ្ងៃដដែល។